# មនុស្សពីរនាក់នៅផ្ទះជិតគ្នា

កាលពីព្រេងនាយមានមនុស្សពីរនាក់នៅផ្ទះជិតគ្នា ។ ថ្ងៃមួយចៅទាំងពីរនាក់នោះបបួលគ្នាទៅដាក់អន្ទាក់សត្វ។ បបួលគ្នាហើយ ដល់ថ្ងៃរសៀលគងភ្នំក៏នាំគ្នាដើរចេញទៅ។ លុះដល់ព្រៃជ្រៅជាកន្លែងដាក់អន្ទាក់អ្នកមួយថា "ខ្ញុំនឹងដាក់នៅលើគល់ឈើនេះដ្បិតឈើនេះមានផ្លែយប់ៗសត្វចំណាំតែមកស៊ីផ្លែឈើនេះ" ។ អ្នកមួយឆ្លើយថា "ខ្ញុំក៏ចង់ដាក់នៅកន្លែងនឹងដែរ ប៉ុន្តែឥឡូវនេះបើអ្នកដាក់នៅលើគល់ឈើ មានតែខ្ញុំដាក់នៅចុងឈើ រួចយើងចាំមើលព្រឹកឡើងរបស់អ្នកណាជាប់សឹមដឹង" ។ និយាយគ្នាហើយម្នាក់ដាក់នៅគល់ឈើម្នាក់ឡើងដាក់នៅចុងឈើ ហើយស្រេចវិលមកផ្ទះវិញរៀងខ្លួន។ ឯអ្នកដាក់អន្ទាក់ដាក់នៅចុងឈើនោះ លុះមកដល់ផ្ទះហើយគិតគ្នាពីរនាក់ប្រពន្ធប្ដីថា "តាំងពីដូនតាមក មិនដែលឮអ្នកឯណាដាក់អន្ទាក់នៅលើចុងឈើឱ្យជាប់សត្វជើងបួនដែលដើរនៅដីទេ ឥឡូវនេះអញដាក់អន្ទាក់នៅលើចុងឈើតើធ្វើមេចនឹងបានសត្វ? ដូច្នេះអញត្រូវរភ្ញាក់ពីពេលមាន់រងាវទៅមើលបើឃើញសត្វជាប់អន្ទាក់គេនៅដី អញដោះយកទៅចងនឹងអន្ទាក់អញឯចុងឈើ ដល់ព្រឹកអញទៅមើលជាមួយអ្នកនោះ ហើយអញដោះសត្វ ទៅជូនលោកសុភាសេក បើវាមិនសុខចិត្តដូចម្ដេចៗមុខជាកើតក្ដីដល់សុភាសេកមិនខាន សុភាសេកមុខជា កាត់ក្ដីឱ្យវាចាញ់អញជាប្រាកដ។ ប្ដីប្រពន្ធគិតគ្នាហើយដេកទៅដល់មាន់រងាវភ្ញាក់ ពីដេកលុបមុខស៊ីស្លាហើយ ចេញពីផ្ទះដើរទៅដល់អន្ទាក់ បានឃើញអន្ទាក់នៅលើដីជាប់ក្ដាន់មួយ ក៏ដោះឡើងយកទៅចងនឹងអន្ទាក់របស់ខ្លួន រួចតំឡើងអន្ទាក់នៅដីដូចដើមក៏ប្រញាប់វិលមកផ្ទះវិញ។ លុះព្រឹកព្រហាមស្រាងៗឡើង អ្នកមួយដែលដាក់អន្ទាក់នៅដីក៏ស្រែកហៅឱ្យទៅមើលអន្ទាក់។ អ្នកមួយឆ្លើយ "កុំរលេះរលាំងថ្វី អន្ទាក់ខ្ញុំៗមិនសង្ឃឹមទេ ដ្បិតនៅលើចុងឈើ រែកងតែអន្ទាក់អ្នក នៅដីនោះខ្ញុំមិនហ៊ានថា បើបានចែកគ្នាស៊ីផង" ។ ពាក្យនេះជាពាក្យចំអកឱ្យអ្នកមួយដ្បិតដឹងការណ៍។ អ្នកទាំងពីរនិយាយហើយ ចុះពីផ្ទះដើរចេញទៅលុះដើរទៅដល់អន្ទាក់មិនឃើញជាប់សត្វនៅលើដី ឃើញជាប់តែនៅលើចុង ឈើវិញ។ ចៅដែលជាម្ចាស់អន្ទាក់នៅលើចុងឈើថា " ន! មើលចុះមិនជឿខ្ញុំថាកុំឱ្យដាក់នៅគល់ ឱ្យដាក់នៅចុងឥឡូវមើលរបស់ អ្នកណាជាប់ហ:?" ហើយឡើងទៅដោះយកចុះមកនាំគ្នាវិលមកផ្ទះវិញ ក៏លាគ្នាទៅផ្ទះដោយខ្លួនទៅ។ ឯចៅដែលបានក្ដាន់ក៏ប្រញាប់យកមកជូនសុភាសេក ហើយជំរាបថា " ខ្ញុំហើយនឹង ចៅមួយនោះទៅដាក់អន្ទាក់ផងគ្នាខ្ញុំដាក់នៅឯចុងឈើ អ្នកមួយនោះដាក់នៅគល់ឈើខ្ញុំនេះជាមនុស្ស វៀចក្ដីគង់តែមកដល់លោក ដូច្នេះតាមតែលោកមេត្តារកសេចក្ដីយាងណាឱ្យតែក្ដីខ្ញុំឈ្នះវាចុះ ខ្ញុំនឹងដឹងគុណលោកទៅថ្ងៃមុខ" ។ សុភាសេកបានសាច់ក្ដាន់ហើយឆ្លើយថា " ឯងទៅរកស្លាម្លូមកឱ្យឆាប់ ឱ្យទាន់ព្រឹកនេះបើវាមកប្ដឹងអញៗបង្គាប់វាអញ្ចឹងដែរ បើវាមកមិនទាន់អញនឹងកាត់សេចក្ដីឱ្យវាចាញ់បានងាយឯងប្រញាប់ទៅចុះ" ។

ឯអ្នកដាក់អន្ទាក់នៅគល់ឈើ លុះវិលមកផ្ទះហើយដង្ហើមតូច ដង្ហើមធំមិនសុខចិត្តក៏យកសេចក្ដីទៅប្ដឹង សុភាសេកៗក៏បង្គាប់សេចក្ដីដូចចៅមុន។ លុះព្រឹកឡើងអ្នកដែលដាក់អន្ទាក់នៅឯចុងឈើក៏យកឥវ៉ាន់ទៅដល់មុន ឯអ្នកដែលដាក់អន្ទាក់នៅដីដោយខ្លួនជាអ្នកក្រលំបាកតោកយ៉ាក ក៏ដើរទៅរកទិញឥវ៉ាន់ពុំបាន ពុំទាន់ភ័យក្រែងខ្លួនចាញ់គេ ហើញគេ

ចាប់ទោសផងក៏រត់ពីភូមិមួយទៅភូមិមួយបានជួបនឹងសុភាទន្សាយៗ សួរថា " មានដំណើរអីបានជារត់ដូច្នេះ? ឈប់សិន" ។ ចៅនោះឆ្លើយថា " លោកអើយអាណិតដោះទុក្ខខ្ញុំផង ដ្បិតខ្ញុំហើយនិងអ្នកមួយទៅដាក់អន្ទាក់ផងគ្នា ខ្ញុំដាក់នៅគល់ឈើ គេដាក់នៅចុងឈើព្រឹកឡើងទៅពុំឃើញនៅដីជាប់សត្វ ឃើញអន្ទាក់ចុងឈើជាប់ក្ដាន់មួយខ្ញុំមិនសុខចិត្តក៏យកសេចក្ដីទៅប្ដឹងសុភាសេក សុភាសេកគេថា " អ្នកណាដើរទៅរកឥវ៉ាន់ទៅដល់មុនអ្នកនោះឈ្នះ " ហេតុនេះបានជាខ្ញុំភ័យឥឡូវគេ ទៅដល់មុនខ្ញុំហើយដូច្នេះតាមតែលោកអាណិតខ្ញុំផង សុភាទន្សាយឆ្លើយថា " ណ្ហើយ! កុំភ័យចាំថ្ងៃ រសៀលខ្ញុំនាំទៅ" ។ ចៅនោះក៏អរ ។ លុះថ្ងៃរសៀលសុភាទន្សាយនាំទៅដល់ ផ្ទះសុភាសេកៗ ស្រែកសួរមកថា " ដូចម្ដេចក៏យូរម្លេះ? សេចក្ដីចាញ់គេហើយ" ។ សុភាទន្សាយឆ្លើយថា " យើងខ្ញុំបានជាយូរនេះពីព្រោះអាល័យតែចាំមើលត្រីក្រាញហើរឡើងស៊ីស្លឹកអំពិល" ។ សុភាសេកសួថា "ពីជីដូនជីតាមកគ្មាននណារដែលឃើញ ដែលឮថាត្រីក្រាញ់ឡើងស៊ីស្លឹកអម្ពិលទេ" ។ សុភាទន្សាយឆ្លើយថា "ពីជីដូន ជីតា ពីម៉ែឪបង្កើតមកនរណាដែលឃើញដែលឮថា អន្ទាក់នៅដីមិនជាប់សត្វ ទៅជាប់អន្ទាក់នៅចុងឈើវិញ ហើយសត្វជើងបួនផង ដែលឮទេ? អស់អ្នកស្រុក!" ។ ខណៈនោះសុភាសេកនៅស្ងៀមពុំហ៊ានស្ដីតបឡើយ ។ សុភាទន្សាយក៏កាត់សេចក្ដីអោយចៅដែលដាក់អន្ទាក់នៅដីឈ្នះ ។ ឯសុភាសេកដែល អង្គុយធ្វើសុភានោះក៏ខ្មាស់គេដោយសារខ្លួនល្មោភជំនួនសាច់ក្ដាន់ក៏ស្ងៀមបែរមុខផ្កាប់ទៅនឹងជញ្ជាំងដូច ឆ្មារលបកណ្ដុរ ។